# MEDIA STATEMENT

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

## អ្នកជំនាញការសិទ្ធិមនុស្ស អ.ស.ប សំដែងការសាទរចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅ កម្ពុជា និងអំពាវនាវឲ្យរក្សាភាពស្ងប់ស្ងាត់ និងឲ្យមានការសម្រុះសម្រួលផ្នែកនយោបាយ

ទីក្រុងហ្សឺណែវ (៣១ កក្កដា ២០១៣) – នៅថ្ងៃនេះ លោក សុរិយា ប្រាសាទ ស៊ូប៉ែឌី អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សនៅកម្ពុជា បានសំដែងការកោតសរសើរដល់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានធ្វើឡើងនៅកម្ពុជា កាលពីថ្ងៃអាទិត្យទី២៨ ខែកក្កដា ឆ្នាំ២០១៣ និងបានអំពាវនាវឲ្យរក្សាភាពស្ងប់ស្ងាត់ និងឲ្យមានការសម្រុះសម្រួលផ្នែកនយោបាយ។

" ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅថ្ងៃអាទិត្យនេះ គឺជាការបង្ហាញពីភាពចាស់ទុំក្នុងការអនុវត្តលិទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសនេះ" លោកបានមានប្រសាសន៍ថា ទន្ទឹមនេះ លោកបានកោតសរសើរដល់តួអង្គនយោបាយទាំងអស់ដែលបានបង្ហាញភាពអត់ធ្មត់របស់ខ្លួន។ " ខ្ញុំសូមសាទរដល់ប្រជាពលរដ្ឋកម្ពុជាដែលបានអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនប្រកបដោយសន្តិវិធី ភាគច្រើនទូទៅ"។

លោកមានប្រសាសន៍ថា " ឥឡូវនេះ ខ្ញុំសូមអំពាវនាវឲ្យរក្សាភាពស្ងប់ស្ងាត់ និងឲ្យមានការសម្រុះសម្រួលផ្នែកនយោបាយ ដើម្បីផលប្រយោជន៍ជាតិធំធេងថែមទៀត និងសូមអំពាវនាវឲ្យពន្លឿនដំណើរការកំណែទម្រង់ស្ថាប័នរដ្ឋ រាប់ទាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីធានាការគោរពសិទ្ធិប្រជាពលរដ្ឋ នីតិរដ្ឋពិតប្រាកដ និងលិទ្ធិប្រជាធិបតេយ្យស៊ីជម្រៅថែមទៀតនៅក្នុងប្រទេសកម្ពុជា" ។

អ្នកជំនាញការសិទ្ធិមនុស្សរូបនេះ ក៏បានអំពាវនាវផងដែរ ដល់ប្រជាពលរដ្ឋ និងតួអង្គនយោបាយទាំងអស់ "មិនត្រូវជម្រុញឲ្យមានការស្អប់ខ្ពើមជាតិសាសន៍ ទោះជាក្នុងលក្ខណៈជាបុគ្គល ឬតាមរយៈមធ្យោបាយដទៃទៀត ដូចជា តាមបណ្តាញព័ត៌មានសង្គមក្តី ហើយត្រូវរួមចំណែកឈានទៅកសាងសង្គមមួយបែបប្រជាធិបតេយ្យសេរី ប្រកបដោយភាពអត់ឱន និងបង្រួបបង្រួមគ្នា។"

ចំពោះការចោទប្រកាន់ជាច្រើនអំពីភាពមិនប្រក្រតី លោក ស៊ូប៉ែឌី បានអំពាវនាវដល់ស្ថាប័នសមស្របទាំងអស់ ឲ្យធ្វើការស៊ើបអង្កេតជាបន្ទាន់ និងដោយគ្មានលំអៀង អំពីភាពមិនប្រក្រតីទាំងនោះ និងបានជម្រុញឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវទទួលខុសត្រូវពន្យល់ទាំងស្រុងអំពីគ្រប់សន្លឹកឆ្នោតដែលមិនបានប្រើប្រាស់។

អ្នករាយការណ៍ពិសេស អ.ស.ប រំលឹកឡើងវិញ អំពីអនុសាសន៍ដែលលោកបានដាក់ចេញដោយផ្ទាល់ ស្តីពីកំណែទម្រង់ការបោះឆ្នោតនៅក្នុងរបាយការណ៍មួយ ដែលបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងខែកញ្ញា ឆ្នាំ២០១២ ដែលអនុសាសន៍ភាគច្រើនមិនត្រូវបានអនុម័តនៅឡើយទេ នៅមុនពេលបោះឆ្នោតនេះ។ លោក

បានសង្កត់ធ្ងន់ថា " ប្រសិនជាអនុសាសន៍ទាំងនេះ ត្រូវបានអនុវត្តទាន់ពេលវេលាសំរាប់ការបោះឆ្នោតនោះ នោះស្ថានភាពបច្ចុប្បន្ន អាចមានលក្ខណៈល្អប្រសើរច្រើនជាងនេះ" ។

**ចប់**

*សាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូបេឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកមិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពនៃបុគ្គលលោកផ្ទាល់ ។ បច្ចុប្បន្នលោកជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ និងជាមេធាវីអាជីពនៅចក្រភពអង់គ្លេស។ លោកក៏ជាបណ្ណាធិការនៃទស្សនាវដ្តីអាស៊ី ផ្នែកនីតិអន្តរជាតិផងដែរ (បោះពុម្ពផ្សាយដោយរោងពុម្ពនៃសាកលវិទ្យាល័យ Cambridge) និងជាអនុប្រធានសង្គមអាស៊ី ផ្នែកនីតិអន្តរជាតិ ។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា ៖*

*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*ផែកមើលរបាយការណ៍ចុងក្រោយបំផុតរបស់អ្នករាយការណ៍ពិសេស ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ៖*

*http://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session21/A-HRC-21-63-Add1_en.pdf*
*សំរាប់ព័តមានបន្ថែម និងការសួរព័ត៌មាន សូមទាក់ទង អលហ្គា ណាកាចូ តាមរយៈទូរស័ព្ទលេខ Tel: + ៤១ ២២ ៩២៨ ៩៣៤៨ អ៊ីម៉ែល onakajo@ohchr.org ឬ សរសេរទៅកាន់ srcambodia@ohchr.org*

សម្រាប់**ការសួរព័ត៌មាន**ទាក់ទងនឹងអ្នកជំនាញការឯករាជ្យរបស់ អ.ស.ប ផ្សេងៗទៀត សូមទំនាក់ទំនង៖
សាប៉ៀរ ស៊ីលាយ៉ា សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ Tel: + ៤១ ២២ ៩១៧ ៩៣៨៣ អ៊ីម៉ែល xcelaya@ohchr.org )

សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមរយៈបណ្តាញព័ត៌មានសង្គម
**ហ្វេសប៊ុក ៖Facebook:** https://www.facebook.com/unitednationshumanrights
**ធ្វីតធឺរ ៖Twitter:** http://twitter.com/UNrightswire
**ហ្គោហ្គឺល ៖Google+** gplus.to/unitednationshumanrights
**យូធូប ៖ YouTube:** http://www.youtube.com/UNOHCHR
**បរិយាយសាច់រឿង៖Storify:** http://storify.com/UNrightswire
**មើល " ប្រស្នា" ៖Watch “The Riddle”:** http://www.youtube.com/embed/sYFNfW1-sM8?rel=0